សេចក្តីប្រកាសព័ត៌មាន

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») ប្រារព្ធទិវាអន្តរជាតិដើម្បីបញ្ចប់និទណ្ឌភាពនៃឧក្រិដ្ឋកម្មលើអ្នកសារព័ត៌មាន

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២៦

កាលពីឆ្នាំ២០១៣ សន្និបាតអង្គការសហប្រជាជាតិបានអនុម័ត និងប្រកាសយកថ្ងៃទី២ ខែវិច្ឆិកា ជាទិវាអន្តរជាតិ ដើម្បីបញ្ចប់និទណ្ឌភាពនៃឧក្រិដ្ឋកម្មលើអ្នកសារព័ត៌មាន។ សេចក្តីសម្រេចនេះថ្កោលទោសគ្រប់ទម្រង់នៃការវាយប្រហារនិងការប្រើអំពើហិង្សាលើអ្នកសារព័ត៌មាន និងអ្នកធ្វើការនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ និងជំរុញរដ្ឋភាគីឱ្យអនុវត្តនូវវិធានការជាក់លាក់ប្រយុទ្ធប្រឆាំងលើវប្បធម៌និទណ្ឌភាព។ ទិវានេះជាការរម្លឹកដល់រដ្ឋ ជាភាគីត្រូវចាត់វិធានការទប់ស្កាត់នូវគ្រប់អំពើហិង្សាលើអ្នកសារព័ត៌មាន និងអ្នកដែលធ្វើការនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ និងធានានូវគណនេយ្យភាព ដោយនាំជនល្មើសមកផ្តន្ទាទោស និងធានាថាជនរងគ្រោះទទួលបាននូវសំណងសមរម្យផងដែរ។ បន្ថែមលើនេះ ទិវានេះក៏អំពាវនាវដល់រដ្ឋជាភាគីក្នុងការលើកកម្ពស់នូវសុវត្ថិភាព និងបង្កបរិយាកាសដែលអ្នកសារព័ត៌មាន អាចបំពេញការងាររបស់ខ្លួនដោយឯករាជ្យ និងមិនមានការជ្រៀតជ្រែក។

ចាប់តាំងពីឆ្នាំ១៩៩៤ មក យ៉ាងហោចណាស់មានអ្នកសារព័ត៌មានចំនួន ១៥នាក់ ត្រូវបានសម្លាប់នៅក្នុងប្រទេសកម្ពុជា ដោយសារការបំពេញការងាររបស់ខ្លួន ដែលក្នុងនោះអ្នកសារព័ត៌មានបរិស្ថានម្នាក់ត្រូវបានគេបាញ់សម្លាប់នៅចុងឆ្នាំ២០២៤ ហើយជនល្មើលត្រូវបានផ្តន្ទាទោសជាក់ពន្ធនាគារយៈពេល ១២ ឆ្នាំ។ នៅក្នុងអំឡុងពេលនោះមក ជនរងគ្រោះចំនួន១២នាក់ស្លាប់ដោយសារពាក់ព័ន្ធនឹងសកម្មភាពរាយការណ៍ព័ត៌មាន ដែលបានប៉ះពាល់ដល់បុគ្គលមានអំណាចនៅកម្ពុជា។ មកដល់បច្ចុប្បន្ននេះ ការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព ឯករាជ្យភាព និងតម្លាភាព មិនត្រូវបានដំណើរការ ដើម្បីនាំជនល្មើសដែលបានប្រព្រឹត្តិបទឧក្រិដ្ឋមកផ្តន្ទាទោសនៅឡើយទេ។ មានករណីជាច្រើនមិនត្រូវបានដោះស្រាយ ហើយជនរងគ្រោះនៅមិនទាន់ទទួលបាននូវយុត្តិធម៌ខណៈដែលជនល្មើសបន្តរួចផុតពីការផ្តន្ទាទោសចំពោះអំពើឧក្រិដ្ឋរបស់ខ្លួន។

ដោយឆ្លុះបញ្ចាំងពីបញ្ហានិទណ្ឌភាពដែលនៅតែបន្តកើតមានលើអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា លោក សេង សុវឌ្ឍនា នាយកប្រតិបត្តិនៃ ម.ស.ម.ក មានប្រសាសន៍ថា៖

«និទណ្ឌភាពមិនត្រឹមតែបដិសេធយុត្តិធម៌សម្រាប់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែវាក៏ប៉ះពាល់ដល់សិទ្ធិ និងសេរីភាពរបស់មនុស្សគ្រប់រូបផងដែរ។ នៅពេលដែលការវាយប្រហារលើអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្សមិនត្រូវបានផ្តន្ទាទោស នាំឱ្យមានការបំបិទសំឡេងរិះគន់ កាត់បន្ថយ

គណនេយ្យភាព និងរារាំងអ្នកដទៃមិនឱ្យហ៊ានបញ្ចេញមតិយោបល់។ រាល់ការវាយប្រហារទាំងអស់ត្រូវតែស៊ើបអង្កេតដោយឯករាជ្យ និងមានតម្លាភាព ហើយជនល្មើស ត្រូវតែនាំយកមកផ្តន្ទាទោសតាមច្បាប់ ។»

ដើម្បីប្រារព្ធទិវាអន្តរជាតិដើម្បីបញ្ចប់និទណ្ឌភាពនៃឧក្រិដ្ឋកម្មលើអ្នកសារព័ត៌មានឆ្នាំ២០២៦ ម.ស.ម.ក នឹងរៀបចំយុទ្ធនាការចាប់ពីថ្ងៃទី០៥ ខែវិច្ឆិកា ដល់ ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៦។ តាមរយៈសកម្មភាពយុទ្ធនាការនេះ ម.ស.ម.ក មានគោលបំណងលើកកម្ពស់ការយល់ដឹងពីផលវិបាកនៃនិទណ្ឌភាព និងអំពាវនាវឱ្យមានការចូលរួមដើម្បីបញ្ចប់និទណ្ឌភាព ។ សូមចូលរួមជាមួយ ម.ស.ម.ក សម្រាប់ព្រឹត្តិការណ៍ដូចខាងក្រោម៖

- ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២៦ ម.ស.ម.ក នឹងផ្សាយឡើងវិញនូវវីដេអូ«ពន្យល់អំពីនិទណ្ឌភាព» ។
- ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២៦ ម.ស.ម.ក នឹងផ្សព្វផ្សាយប័ណ្ណព័ត៌មានដើម្បីស្វែងរកមតិយោបល់ពីសាធារណជនអំពីបញ្ហានិទណ្ឌភាព។
- ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២៦ ម.ស.ម.ក នឹងផ្សាយឡើងវិញនូវវីដេអូ«**អ្នកបន្តវេន**» ដែលរៀបរាប់ពីកូនប្រុសរបស់អ្នកសារព័ត៌មានម្នាក់ដែលត្រូវបានសម្លាប់ និងការព្យាយាមក្នុងការស្វែងរកយុត្តិធម៌ជូនឪពុករបស់ខ្លួន។
- ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៦ ម.ស.ម.ក នឹងផ្សព្វផ្សាយពីកម្រងជីវប្រវត្តិអ្នកសារព័ត៌មានដែលរងនូវនិទណ្ឌភាព។
- ថ្ងៃទី១១ និងថ្ងៃទី១២ ឆ្នាំ២០២៦ ម.ស.ម.ក នឹងផ្សព្វផ្សាយវីដេអូខ្លីចេញពីកម្មវិធីវិទ្យុកាលពីថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២៦ ក្រោមប្រធានបទ «ផលវិបាកនៃនិទណ្ឌភាព» ។
- ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៦ ម.ស.ម.ក នឹងផ្សព្វផ្សាយផ្ទាល់កិច្ចពិភាក្សាប្រធានបទ«រួមគ្នាដើម្បីបញ្ចប់និទណ្ឌភាព» ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកអ្នកសម្របសម្រួលគម្រោងនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា លោក ហួន ផន តាមរយៈអ៊ីម៉ែល phorn@cchrcambodia.org ឬ ០៧០ ៧៥៧ ៨៨៤ ៕

ចប់

បណ្ណាធិការ៖

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "ម.ស.ម.ក" បានបង្កើតឡើងក្នុង ខែវិច្ឆិកា ឆ្នាំ២០០២ គឺជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ពន្ធ ដែលធ្វើការលើកកម្ពស់ និងការពារលិទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

ម.ស.ម.ក គឺជាសមាជិកនៃ អង្គការផ្លាស់ប្តូរសេរីភាពបញ្ចេញមតិអន្តរជាតិ (IFEX) ដែលជាបណ្តាញសកលសម្រាប់សេរីភាពនៃការបញ្ចេញមតិ និង CIVICUS ៖ សម្ព័ន្ធពិភពលោកសម្រាប់ការចូលរួមរបស់ពលរដ្ឋ។

ម.ស.ម.ក ក៏ជាសមាជិកនៃអង្គការប្រឆាំងទារុណកម្មពិភពលោក (MOCT SOS-Torture Network) និង ជាសមាជិក OECD Watch ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ទទួលបានពានរង្វាន់ពីមូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ "សិទ្ធិ និង សេរីភាព" និងទទួលពានរង្វាន់ ទំនាក់ទំនងសម្រាប់ការផ្លាស់ប្តូរសង្គម មកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនង និងផ្លាស់ប្តូរសង្គម នៅសាកលវិទ្យាល័យឃ្វីនឡែនក្នុងទីក្រុងប្រ៊ីសបែន (Brisbane) នៃប្រទេសអូស្ត្រាលី។